# ព័ត៌មានអំពីសម្បទានដីសង្គមកិច្ច

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច
និងការអភិវឌ្ឍសេដ្ឋកិច្ច

*LASED គឺជាគម្រោងបែងចែកដីសម្បទានសង្គមកិច្ច នៅខេត្តក្រចេះ កំពង់ចាម និងកំពង់ធំ ដោយផ្តល់ដីឯកជនរបស់រដ្ឋដល់គ្រួសារប្រជាពលរដ្ឋក្រីក្រដែលគ្មានដី និងខ្វះដីពិតប្រាកដ ព្រមទាំងផ្តល់សេវាគាំទ្រអភិវឌ្ឍជនបទចាំបាច់មួយចំនួនដល់គ្រួសារទទួលបានដីទាំងនោះសម្រាប់ជួយដល់ការចិញ្ចឹមជីវិតរបស់ពួកគាត់។*

## តើខ្ញុំអាចដឹងពីគម្រោង LASED ដោយរបៀបណា?

ភូមិ ឃុំ នឹងប្រកាសផ្សព្វផ្សាយអំពីពេលវេលា ទីកន្លែង និងរបៀបដាក់ពាក្យសុំសម្បទានដីសង្គមកិច្ចនៃគម្រោង LASED ក្នុងរយៈពេល ៣០ថ្ងៃ ដោយមានការប្រជុំតាមភូមិ ការផ្សព្វផ្សាយតាមមេក្រូ និងការបិទសេចក្តីជូនដំណឹងផ្សព្វផ្សាយព័ត៌មានជាសាធារណៈតាមភូមិនីមួយៗ។ អ្នកអាចទាក់ទងមេភូមិ មេឃុំ ក្រុមប្រឹក្សាឃុំ អង្គការ GTZ/IP-GOPA ឬអង្គការវឌ្ឍនភាព ដើម្បីសាកសួរព័ត៌មានបន្ថែម។

## តើខ្ញុំអាចដាក់ពាក្យសុំសម្បទានដីសង្គមកិច្ចនៃគម្រោង LASED ដោយរបៀបណា?

ទៅសាលាឃុំ និងយកពាក្យសុំសម្បទានដីសង្គមកិច្ចដោយមិនគិតថ្លៃ។ ប្រសិនបើអ្នកត្រូវការជំនួយផ្សេងៗទាក់ទងនឹង ការបំពេញការដាក់ពាក្យ សូមទាក់ទងមេភូមិ មេឃុំ ក្រុមប្រឹក្សាឃុំ អង្គការក្នុងស្រុក ឬអ្នកចេះអក្សរក្នុងភូមិ ហើយអ្នកមិនគួរចំណាយប្រាក់ឡើយ។

## តើខ្ញុំអាចដាក់ពាក្យសុំសម្បទានដីសង្គមកិច្ចនៃគម្រោង LASED នៅពេលណា និងកន្លែងណា?

បន្ទាប់ពីផ្សព្វផ្សាយឲ្យមានការដាក់ពាក្យសុំអស់រយៈពេល ៣០ថ្ងៃរួចមកអ្នកនឹងមានរយៈពេល ២០ថ្ងៃ បន្ថែមទៀតក្នុងរាល់ម៉ោងធ្វើការ ដើម្បីដាក់ពាក្យសុំសម្បទានដីសង្គមកិច្ចនៃគម្រោង LASED នៅសាលាឃុំរបស់អ្នក។

## តើមានឯកសារអ្វីខ្លះដែលខ្ញុំត្រូវភ្ជាប់ជាមួយពាក្យសុំសម្បទានដីសង្គមកិច្ចនៃគម្រោង LASED?

ឯកសារដែលត្រូវភ្ជាប់ជាមួយពាក្យសុំមានដូចជា:

- រូបថត ៤ គុណ ៦ ចំនួនមួយសន្លឹក
- សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ ឬអត្តសញ្ញាណប័ណ្ណ










ព័ត៌មានក្នុងពាក្យសុំ នឹងត្រូវបញ្ជាក់ពីសុពលភាពឲ្យបានត្រឹមត្រូវ ដើម្បីធានាដល់ការជ្រើសរើសក្នុងគម្រោងសម្បទានដីសង្គមកិច្ច ហើយពាក្យសុំទាំងអស់នឹងរក្សាទុកនៅសាលាឃុំដើម្បីធ្វើការត្រួតពិនិត្យ និងទុកជាឯកសារ។

## តើខ្ញុំត្រូវមានលក្ខណៈសម្បត្តិអ្វីខ្លះដើម្បីដាក់ពាក្យសុំសម្បទានដីសង្គមកិច្ចនៃគម្រោង LASED?

ដើម្បីដាក់ពាក្យសុំសម្បទានដីសង្គមកិច្ច អ្នកត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម:

- ត្រូវមានសញ្ជាតិខ្មែរ
- ជាគ្រួសារក្រីក្រដែលគ្មានដីសោះ និងមានដីតិចតួច
- ជាមេគ្រួសារ ដែលមានសមាជិកចាប់ពី ២នាក់ឡើងទៅ
- មានឆន្ទៈ និងសមត្ថភាពចូលរួមក្នុងកម្មវិធីសម្បទានដីសង្គមកិច្ច
- មិនធ្លាប់បានទទួលសម្បទានដីសង្គមកិច្ចពីមុនមក

## តើគ្រួសារដែលត្រូវជ្រើសរើសជាអ្នកទទួលសម្បទានដីសង្គមកិច្ចនៃគម្រោង LASED មានកត្តាដូចម្តេច?

គ្រួសារជាច្រើន នឹងដាក់ពាក្យសុំដី ប៉ុន្តែមិនមែនគ្រួសារទាំងអស់នឹងទទួលបានដីឡើយ។ ការជ្រើសរើសអាស្រ័យលើកត្តាមួយចំនួនដូចជា:

- រយៈពេលរស់នៅក្នុងឃុំ
- កម្រិតភាពក្រីក្រ និងបរិមាណដីដែលបានកាន់កាប់

## តើខ្ញុំអាចដឹងពីលទ្ធផលនៃការជ្រើសរើសមុខសញ្ញាអ្នកទទួលដីដោយរបៀបណា?

បញ្ជីអ្នកដែលត្រូវបានជ្រើសរើសបឋម នឹងត្រូវបិទបង្ហាញតាមភូមិ។ ដូចនេះ អ្នកអាចដឹងថាតើ និងមូលហេតុអ្វីខ្លះដែលអ្នកត្រូវបានជ្រើសរើស។ បន្ទាប់មកនឹងរៀបចំអង្គប្រជុំជាសាធារណៈ ដើម្បីពិភាក្សាលទ្ធផលនៃការជ្រើសរើស។



## តើខ្ញុំអាចប្តឹងតវ៉ាដោយរបៀបណាក្នុងករណីខ្ញុំមិនពេញចិត្ត នឹងការជ្រើសរើស?

ប្រសិនបើអ្នកមិនពេញចិត្តជាមួយលទ្ធផលនៃការជ្រើសរើស អ្នកអាចដាក់ពាក្យបណ្តឹងតវ៉ាមកសាលាឃុំ ឬដាក់ក្នុងប្រអប់សំបុត្រទទួលបណ្តឹងតវ៉ាតាមភូមិដែលខ្លួនរស់នៅ។ អ្នកនឹងអាចទទួលបានការឆ្លើយបំភ្លឺក្នុងរយៈពេល ៣០ថ្ងៃ ក្រោយពេលក្រុមប្រឹក្សាឃុំទទួលបានពាក្យបណ្តឹង។

## តើអ្នកទទួលខុសត្រូវអ្វីខ្លះក្រោយពីទទួលបានសម្បទានដីសង្គមកិច្ចនៃគម្រោង LASED?

- បើសិនអ្នកទទួលបានដីកសិកម្ម អ្នកត្រូវចាប់ផ្តើមដាំដំណាំលើដីនោះក្នុងរយៈពេល ១២ ខែដំបូង ហើយបន្តប្រើប្រាស់ដីនេះរហូតតទៅ។
- បើសិនអ្នកទទួលបានដីលំនៅឋាន អ្នកត្រូវតែសាងសង់ផ្នែកណាមួយនៃលំនៅឋានក្នុងរយៈពេល ៣ខែដំបូង។ អ្នក ឬសមាជិកគ្រួសារត្រូវរស់នៅលើដីលំនៅឋាននោះយ៉ាងតិចរយៈពេល ៦ខែក្នុងមួយឆ្នាំ។
- មិនអនុញ្ញាតអោយលក់ ឬជួលសម្បទានដីសង្គមកិច្ចនោះបានទេ។ ប្រសិនបើជាអ្នកទទួលបានសម្បទានដីសង្គមកិច្ចស្លាប់ក្នុងរយៈពេលអនុវត្តន៍គម្រោង នោះសមាជិកក្នុងគ្រួសារមានសិទ្ធិអាចបន្តអនុវត្តន៍លក្ខខណ្ឌសម្បទានដីសង្គមកិច្ចបាន។
- បន្ទាប់ពីរយៈពេល ៥ឆ្នាំដែលបានបន្តប្រើប្រាស់ និងបំពេញលក្ខខណ្ឌទាំងអស់នៅក្នុងកិច្ចព្រមព្រៀង អ្នកទទួលបានសម្បទានដីសង្គមកិច្ចមានសិទ្ធិកម្មសិទ្ធិលើដីនោះ និងអាចស្នើសុំប័ណ្ណកម្មសិទ្ធិ ប៉ុន្តែប្រសិនបើមិនបានបំពេញតាមលក្ខខណ្ឌក្នុងកិច្ចព្រមព្រៀងទេ អ្នកនឹងត្រូវបានរដ្ឋដកហូតសម្បទានដីសង្គមកិច្ចនោះ ដើម្បីបែងចែកអោយអ្នកផ្សេង។

## តើគម្រោង LASED ផ្តល់សេវាគាំទ្រអ្វីខ្លះដល់គ្រួសារដែលទទួលបានសម្បទានដីសង្គមកិច្ច?

អ្នកនឹងទទួលបានការគាំទ្រសម្រាប់ចិញ្ចឹមជីវិត តាមរយៈកម្មវិធី "ស្បៀងពលកម្ម" នាឆ្នាំដំបូងរហូតដល់អ្នកបានប្រមូលកសិផលដំបូងរបស់អ្នក។ កម្មវិធី "ស្បៀងពលកម្ម" នេះគឺដើម្បីជួយអ្នកក្នុងការសាងសង់ជម្រក រៀបចំសំអាតដីកសិកម្ម និងដាំដុះ។

គម្រោងនឹងផ្តល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទចាំបាច់មួយចំនួនដូចជា កសាងផ្លូវលំជនបទក្នុងទីតាំងសម្បទានដីសង្គមកិច្ច និងជីកអណ្តូងដើម្បីផ្គត់ផ្គង់ទឹកស្អាត។

អ្នកអាចចូលរួមយោបល់បាន ក្នុងពេលរៀបចំផែនការប្រើប្រាស់ និងបែងចែកដីសម្បទានសង្គមកិច្ច ផែនការសេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជាសាលារៀន មណ្ឌលសុខភាព ឬប្រព័ន្ធធារាសាស្ត្រខ្នាតតូច។

ប្រសិនបើអ្នកទទួលបានដីលំនៅឋាន អ្នកនឹងទទួលបានកញ្ចប់ឧបត្ថម្ភដំបូងដូចខាងក្រោម:

- សម្ភារៈប្រើប្រាស់ក្នុងផ្ទះចាំបាច់មួយចំនួន និងគ្រាប់ពូជសម្រាប់ដាំដុះដំណាំនៅជុំវិញផ្ទះ។

ប្រសិនបើអ្នកទទួលបានដីកសិកម្ម អ្នកនឹងទទួលបានកញ្ចប់ឧបត្ថម្ភដំបូងរួមមាន:

- ឧបករណ៍កសិកម្ម គ្រាប់ពូជ និងជីរ សម្រាប់រដូវដាំដុះដំបូង។
- សេវាកម្មគាំទ្រផ្នែកកសិកម្ម គឺបណ្តុះបណ្តាលអ្នកឲ្យយល់ដឹងពីមធ្យោបាយធ្វើកសិកម្ម និងការលក់ផលិតផលកសិកម្ម។

## តើខ្ញុំអាចទទួលព័ត៌មានបន្ថែមពីគម្រោង LASED បានដោយរបៀបណា?

សម្រាប់ព័ត៌មានបន្ថែមពីសម្បទានដីសង្គមកិច្ចនៃគម្រោង LASED សូមទំនាក់ទំនង:

- មេភូមិ ឬសាលាឃុំ
- ការិយាល័យភូមិបាលស្រុក ឬមន្ទីររៀបចំដែនដីរាជធានី/ខេត្ត
- អគ្គលេខាធិការដ្ឋានសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

បោះពុម្ពឡើងវិញដោយគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច
នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
នៅ ខែធ្នូ ឆ្នាំ ២០១១
អាសយដ្ឋាន: ផ្លូវលេខ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់ បឹងត្របែក
ខ័ណ្ឌចំការមន រាជធានីភ្នំពេញ, Email: lased@ezecom.com.kh
ទូរស័ព្ទ និងទូរសារ: ០២៣៩៩៧ ៦០៦

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

ក្រសួងមហាផ្ទៃ

គាំទ្រដោយ ក្រសួងអភិវឌ្ឍន៍ និង កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច នៃសហព័ន្ធអាល្លឺម៉ង់ (BMZ) តាមរយៈកិច្ចសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ GIZ
(Deutsche Gesellschaft für Technische Zusammenarbeit GmbH)